បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 17 ខែ 6 ឆ្នាំ 2003

## មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០១-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៨៩ តែងតាំងឯកឧត្តម **នុប សំ** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជ្រើសតាំងដោយរដ្ឋសភាសំរាប់អាណត្តិថ្មី ១៤៧៦

០២-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩០ តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈជូនចំពោះលោកឧត្តមសេនីយ៍ត្រី **អ៊ឹក ប្រុនរ៉ាត** ១៤៧៧

០២-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩១ តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈ ជូនចំពោះលោក ឧត្តមសេនីយ៍ទោ **គឹម រាជ** ១៤៧៨

០២-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩២ បញ្ឈប់ភារកិច្ចឯកឧត្តម **វណ្ណា មូលីវណ្ណ** ពីប្រធានអគ្គនាយកនៃ អាជ្ញាធរអប្សរា ១៤៧៩

០៦-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩៣ ផ្តល់សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ដល់លោក **ផង់ គង់យួង** ១៤៨១

០៦-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩៤ ដកហូតឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី ពីលោក **រស់ សារី** ប្រធាននាយកដ្ឋានសុខាភិបាល ក្រសួងមហាផ្ទៃ ១៤៨២

០៧-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០១ តែងតាំងលោកជំទាវ **ហួរ ស៊ី** ជាអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ១៤៨៣

១៥-៦-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០៣ តែងតាំងលោកជំទាវ **ស៊ុយ នូ** នាមដើម **ហួតានីកា** ជាទីប្រឹក្សាផ្ទាល់ប្រធានរដ្ឋសភា ១៤៨៤

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០៥-៦-២០០១ -អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៤៨៥

០៥-៦-២០០១ -អនុក្រឹត្យលេខ ៤៨ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៤៨៧

០៥-៦-២០០១ -អនុក្រឹត្យលេខ ៤៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៤៨៨

០៤-៦-២០០១ -អនុក្រឹត្យលេខ ២៤៦ អនក្រ.បក ស្តីពីការដកហូតឋានន្តរសក្តិនាយនគរបាលជាតិ ១៤៩០

០៤-៦-២០០១ -អនុក្រឹត្យលេខ ២៤៧ អនក្រ.បក ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៩២

០៥-៦-២០០១ -អនុក្រឹត្យលេខ ២៤៨ អនក្រ.បក ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៩៣

០៥-៦-២០០១ -អនុក្រឹត្យលេខ ២៤៩ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៩៤

០៥-៦-២០០១ -អនុក្រឹត្យលេខ ២៥០ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៩៥

០៥-៦-២០០១ -អនុក្រឹត្យលេខ ២៥១ អនក្រ.បក ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៩៦


## ២_សេចក្តីសំរេច


០៥-៦-២០០១ -សេចក្តីសំរេចលេខ ២៨ សសរ ស្តីពីការផ្ទេរសិទ្ធិ ដែរាជរដ្ឋាភិបាល ១៤៩៨

០៥-៦-២០០១ -DECISION N; 30 SSR appointment of an Economies Advisor to the Prime Minister of the Kingdom of Cambodia ១៤៩៩

០៥-៦-២០០១ -សេចក្តីសំរេចលេខ ៣១ សសរ ស្តីពីការបង្កើតគណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យ ករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម **ឈុន យ៉ាសិទ្ធិ** ១៤៩៩

០៨-៦-២០០១ -សេចក្តីសំរេចលេខ ៣២ សសរ ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រី ១៥០២


## III-ការិយាល័យបណ្តាក្រសួង

## ១_ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស


០៤-៦-២០០១ -ប្រកាសលេខ ៣៨៧ ឧរថ ឧកស.ប្រក អនុញ្ញាតអោយលោក **សោម ស៊ីវ** ជន ជាតិខ្មែរ បន្តដំណើរការឧស្សាហកម្មតូចផលិតគ្រឿងបន្លាស់អំពីកៅស៊ូសំរាប់ម៉ូតូ រថយន្ត ១៥០៣.

០៤-៦-២០០១ -ប្រកាសលេខ ៣៨៨ ឧរថ.ឧកស.ប្រក អនុញ្ញាតអោយលោក **ទិញ ទ្រី** បន្តដំណើរការឧស្សាហកម្មតូចផលិតប្រេងរំអិល " COSMIC " ១៥០៤

១៤-៦-២០០១ -ប្រកាសលេខ ៤០០ ឧរថក ឧ.ប្រក ១៥០៦

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស

០៧-៦-២០០១ -ប្រកាសលេខ ៣៩៨ អយក.ប្រក ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យរលាប្អៀរជើង ទៅជាវិទ្យាល័យ ហ៊ុន សែន រលាប្អៀរ ស្ថិតនៅក្នុងឃុំពង្រ ស្រុករលាប្អៀរ ខេត្ត កំពង់ឆ្នាំង ១៥០៨

០៧-៦-២០០១ -ប្រកាសលេខ ៤០០ អយក.ប្រក ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យរលាប្អៀរ ទៅជា វិទ្យាល័យ ប៊ុន រានី ហ៊ុន សែន រលាប្អៀរ ស្ថិតនៅក្នុងឃុំ អណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ១៥០៩

០៧-៦-២០០១ -ប្រកាសលេខ ៤០៤ អយក.ប្រក ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ " បរិបូណ៌ " ទៅជាវិទ្យាល័យ ហ៊ុន សែន បរិបូណ៌ ស្ថិតនៅក្នុងឃុំ ខុនរ៉ង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ១៥១១

## ៣-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

### ប្រកាស

១៥-៦-២០០១ -ប្រកាសលេខ ១២៤ សកប.យ ស្តីពីការលើកដាក់ទម្ងន់ដោយកំលាំងពលកម្ម ១៥១៣

## ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

### ប្រកាស

០៧-៦-២០០១ -ប្រកាសលេខ ១៩៦ ប្រក សក.បច ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥១៥

# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៨៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា និងលទ្ធផលបោះឆ្នោតជ្រើសតាំងដោយសម្ងាត់ នៃអង្គសភា កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងឯកឧត្តម **នុប សំ** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជ្រើសតាំងដោយរដ្ឋសភា សំរាប់អាណត្តិថ្មី ។

**មាត្រា ២ .-** ក្រុមប្រឹក្សាធម្មនុញ្ញ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩០

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំការ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈជូនចំពោះសពឧត្តមសេនីយ៍ត្រី **អ៊ុក ប្រុណិត** ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

===

## ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ

-បានទ្រង់យល់សំណើររបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទិ ២៣ ខែ ឧសភា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានតម្លើងឋានន្តរស័ក្ក ថ្នាក់ ឧត្តមសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈជូនចំពោះ សពឧត្តមសេនីយ៍ទោ **គឹម អាន់** ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២.-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

**ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩២**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និង រៀបចំតំបន់អង្គរ ហៅថា " អាជ្ញាធរអប្សរា "

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

-យោងតាមសំណើររបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១ ..** ត្រូវបញ្ឈប់ភារកិច្ច ឯកឧត្តម **វណ្ណ មូលីវណ្ណ** ពីប្រធានអគ្គនាយកនៃ " អាជ្ញាធរអប្សរា "

**មាត្រា ២** .- ត្រូវបានតម្លើងឋានៈ និង តែងតាំង :

១-ឯកឧត្តម **ប៊ុន ណារិទ្ធ** ជាប្រធានអគ្គនាយកនៃ " អាជ្ញាធរអប្សរា " មានឋានៈស្មើ រដ្ឋលេខាធិការ

២-ឯកឧត្តម **រស់ បូរ៉ាត់** ជាអគ្គនាយករងនៃ " អាជ្ញាធរអប្សរា " មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣-ឯកឧត្តម **អ៊ឹក សូមេត្ត** ជាអគ្គនាយករងនៃ " អាជ្ញាធរអប្សរា " មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៤ ឯកឧត្តម **ស៊ឹម កា** ជាអគ្គនាយករងនៃ " អាជ្ញាធរអប្សរា " មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៥-ឯកឧត្តម **តាន់ សំប៊ុន** ជាអគ្គនាយករងនៃ " អាជ្ញាធរអប្សរា " មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៦-ឯកឧត្តម **ទេព ហែន** ជាអគ្គនាយករងនៃ " អាជ្ញាធរអប្សរា " មានឋានៈស្មើ អនុរដ្ឋលេខាធិការ

**មាត្រា ៣** .- ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៩ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជា និរាករណ៍ ។

**មាត្រា ៤** .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

**មាត្រា ៥** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦** .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

===

# ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១** .- ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់លោក **ផន់ គន់យួង** ( FAN KUANG YUNG ) ហៅ **លីវ ឈីងហួរ** សញ្ជាតិដើមចិន កើតថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៥២ នៅកោះតៃវ៉ាន់ប្រទេសចិន ។

**មាត្រា ២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ នស/រកត/០៦០១/១៩៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១** .- ត្រូវបានដកហូតឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ពីលោក **រស់ សារី** ប្រធាននាយកដ្ឋានសុខាភិបាល នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** .- លោក **រស់ សារី** ត្រូវបានទទួលឋានន្តរស័ក្តិ ទៅតាមការសំរេចរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ៣** .- រាល់ការកំណត់ទាំងឡាយណាដែលផ្ទុយពី ព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

===

**ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០១**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០១ ០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១** .- ត្រូវបានតែងតាំង លោកជំទាវ **ហួរ ស៊ី** ជាអគ្គលេខាធិការ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

===

**ព្រះរាជក្រឹត្យ នស/រកត/០៦០១/២០៣**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃ រដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឬទ្ធិ** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា លេខ ៣៧៤ រស ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១

-យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

**មាត្រា ១** .- តែងតាំងលោកជំទាវ **ស៊ុយ នូ** នាមដើម **ហូ ភានីភា** ជាទីប្រឹក្សាផ្ទាល់ប្រធានរដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២** .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

===

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

## អនុក្រឹត្យលេខ ៤៧ អនក្រ.បក
## ស្តីពីការផ្ទេរសណ្ឋានដំណ្ឋាន

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់

គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៣.០០០ លានរៀល ( បីពាន់លានរៀល ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា ២ .-** ឥណទានថវិកា ក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតិអោយប្រើប្រាស់ សំរាប់រៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីស្តីទី

**អ៊ុក រ៉ាប៊ុន**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# អនុក្រឹត្យលេខ ៤៨ អនក្រ.បក
## ស្តីពីការផ្ទេរឥណទានថវិកា

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា

-តាមសំណើររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ២០០ លានរៀល ( ពីរយលានរៀល ) ពីជំពូក ៤១ ( ចំណាយមិនគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយរដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងរៀបរយដែនដីនគរូបនីយកម្ម និងសំណង់ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា ២ .-** ការបែងចែក ឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ដំណើរការរដ្ឋបាល របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

---

## អនុក្រឹត្យលេខ ៤៩ អនក្រ.បក

## ស្តីពីការផ្ទេរឥណទានថវិកា

---

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៩ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា

-តាមសំណើររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ២.៤៥០ លានរៀល ( ពីពាន់បួនរយកៅសិបលានរៀល ) ពីជំពូក ៤១ ( ចំណាយមិនគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក

មកជំពូក ១១ ( ចំណាយ ដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងបរិស្ថាន សំរាប់ការ គ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា ២ .-** ការបែងចែក ឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចំណាយទិញឯកសណ្ឋាន ឧបករណ៍សំភារៈរៀបចំជារថយន្តស៊ីទែនចំណុះ ១០.០០០លីត្រ ចំនួន ៦ គ្រឿង សំរាប់ពន្លត់អគ្គីភ័យ តាមតំបន់ឧទ្យានជាតិនានា ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

===

## អនុក្រឹត្យលេខ ២៤៦ អនក្រ.គត

## ស្តីពីការដកហូតឋានន្តរស័ក្តិនាយនគរបាលជាតិ

---

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១** .- ត្រូវបានដកហូតឋាន្តរស័ក្តិថ្នាក់វរសេនីយ៍ឯកពីនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចបានរាយជាបខាងក្រោម :

១-លោកវរសេនីយ៍ឯក **កែវ ភួន** មន្ត្រីនគរបាលជាតិ

២-លោកវរសេនីយ៍ឯក **ខេស សំ** មន្ត្រីនគរបាលជាតិ

**មាត្រា ២** .- អស់លោកដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវទទួលឋាន្តរស័ក្តិ ទៅតាមការសំរេច របស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៣** .- រាល់ការកំណត់ទាំងឡាយណាដែលផ្ទុយពី អនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ២៤៧ អនក្រ.តត**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ " **ធិបឌិន្ទ** " ប្រគេន និងជូនលោកគ្រូ ដែលបានប្រឹងប្រែងយកអស់កំលាំងកាយ កំលាំងចិត្ត និង បានចំណាយនូវបច្ច័យ និង ថវិកាផ្ទាល់រៀង១ខ្លួន ដើម្បីជួយកសាងព្រះវិហារ ឧបដ្ឋានសាលា របង ក្លោងទ្វារ សាលាធម្មវិន័យ ហោត្រ័យ ចាក់ដី បំពេញវត្ត ជួសជុលលើកទំនប់ លើកផ្លូវ សាលារៀន កុដិ សាលាបុណ្យព្រះពន្លៃ កសាងវត្តក្នុងស្រុក និងក្រៅស្រុកចំនួន ១១ វត្ត ព្រមទាំងបានចែក អំណោយជូនប្រជាជនក្រីក្រចំនួន ២១០ គ្រួសារដូចមានរាយព្រះនាម និងនាមខាងក្រោម :

១-ព្រះតេជគុណ **នូ ផល្លា** ចៅអធិការវត្តធម្មស្រះ ឃុំភ្នំបាត ឃុំ ពញាពន់ បច្ច័យ ចំនួន ២៤៦.២៤៣ USD

២-លោកគ្រូ **រស់ សារិន** ប្រធានគណៈកម្មការសាងសង់វត្តសុវណ្ណធម្មរាជ ឃុំពញាពន់ ថវិកាចំនួន ២៣៨.០៦១ USDនិង៥៩.៦០០.០០០រៀល

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

## អនុក្រឹត្យលេខ ២៤៨ អនក្រ.តត
## ស្ដីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១០ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកិច្ចការនារី និងយុទ្ធជន

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០១/០៣៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០១ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី

-បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន

-សំណើរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតិតយុទ្ធជន និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី

**សំរេច**

**មាត្រា ១ .-** ត្រូវបានតែងតាំង :

-លោកស្រីវេជ្ជបណ្ឌិត **នុច រដ្ឋាទី** បច្ចុប្បន្នមន្ត្រីនៃក្រសួងសុខាភិបាល ជាអគ្គលេខាធិការរង នៃ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី មានឋានៈស្មើនឹង **អគ្គនាយករង**

-លោកស្រី **ចាន់ សុទ្ធាវី** បច្ចុប្បន្នមន្ត្រីនៃក្រសួងយុត្តិធម៌ ជាអគ្គលេខាធិការរងនៃ ក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី មានឋានៈស្មើនឹង **អគ្គនាយករង**

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តធម៌ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

===

**អនុក្រឹត្យលេខ ២៤៩ អនក្រ.តត**

**ស្តីពីការរុះរើដោយស្លាបនាជាតិ**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា ១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាង សាលារៀន ព្រះវិហារ សាលាធម្មសភា និង ជីកស្រះ ក្នុងវត្តអង្គបរិច្ចាគ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ :

១-ព្រះតេជគុណ **ឈឹម យឿក** ព្រះចៅអធិការវត្តអង្គបរិច្ចាគ បច្ច័យចំនួន ១៣.៥០០ USD

២-ឧបាសិកា **ខាង អ៊ីង** ថវិកាចំនួន ១២.៣០០ USD

**មាត្រា ២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

## អនុក្រឹត្យលេខ ២៥០ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា ១** .- ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ខ្មែររស់នៅសហរដ្ឋអាមេរិក ចំនួន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាង ព្រះវិហារ ស្រះទឹក និងព្រះពុទ្ធរូប ចំនួន ០៥ អង្គ ក្នុងវត្តសិរិទ្ធិវង្ស ឃុំតាអូ ស្រុកគិរីវង់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ :

១-លោកតា **សុខ សាំង** ថវិកាចំនួន ១៨.២៧៥ ដុល្លារអាមេរិក

២-លោកស្រី **ង៉ែត ស៊ីម** ថវិកាចំនួន ១២.៤០២ ដុល្លារអាមេរិក .

**មាត្រា ២** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

===

**អនុក្រឹត្យលេខ ២៥១ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជនចំនួន ១០ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាង កុដិ ០១ ខ្នង ពីរជាន់ សាលាធម្មសភា ០១ ខ្នង និង សមិទ្ធផលផ្សេងៗ ក្នុងវត្តតុំ ឃុំរកាក្រៅ ស្រុកដូនកែវ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោមនេះ :

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ **កែវ សារ៉ាន** | បច្ច័យចំនួន | ១២.១០០ | ដុល្លារអាមេរិក |
| ២-ឧបាសិកា **គាត់ ឡឹម** | ថវិកាចំនួន | ១០.០៥០ | ដុល្លារអាមេរិក |
| ៣-ឧបាសិកា **សុខ ជុំ** | ថវិកាចំនួន | ១០.០៣០ | ដុល្លារអាមេរិក |
| ៤-លោក **និត ជា** | ថវិកាចំនួន | ១០.២០០ | ដុល្លារអាមេរិក |
| ៥-លោកវរសេនីយ៍ទោ **នៅ សារ៉ាន** | ថវិកាចំនួន | ១០.០០០ | ដុល្លារអាមេរិក |
| ៦-លោក **ស៊ិត ម៉ុង** | ថវិកាចំនួន | ១០.០០០ | ដុល្លារអាមេរិក |

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក **ទ្រាង សេ** | ថវិកាចំនួន | ៦.៣០០ | ដុល្លារអាមេរិក |
| ២-លោក **យិន សុផស** | ថវិកាចំនួន | ៥.៧៥០ | ដុល្លារអាមេរិក |

**គ.មេដាយសំរិទ្ធិស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា **ស ឆោន** | ថវិកាចំនួន | ៤.០០០ | ដុល្លារអាមេរិក |
| ២-លោក **អ៊ុន ឆន** | ថវិកាចំនួន | ២.៥០០ | ដុល្លារអាមេរិក |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# ២_សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ២៩ សសរ**

**ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល**

===

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅប្រទេសជប៉ុន ដើម្បីចូលរួមសន្និសីទអន្តរជាតិស្តីពីអនាគតអាស៊ី ទស្សនកិច្ចនៅខេត្តអូអ៊ីតានិងចូលរួមកិច្ចប្រជុំក្រុមពិគ្រោះយោបល់ជាមួយសហគមន៍អ្នកផ្តល់ជំនួយ ចាប់ពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០១ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និង ឯកឧត្តម **ស ខេង** ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**Decision**
**N.30 SSR**
**The appointment of an Economic Advisor to the Prime Minister of the Kingdom of Cambodia**

000

**The Royal Government**

- Having seen the constiution of the Kingdom of Cambodia
-Having seen the RoyalDecree N NS.RKT.1198.72 dated November 30 th 1998 on the appointment of the Royal Govrnmemt of the Kingdom of Cambodia
-Having seen the Reachkrom N 02.NS.94 dated july 20 th 1994 which promulgated the law on the organization and functioning of the Council of Ministers
-Pursuant to the needs of the Royal Govrnment of Cambodta

**Hereby Decides :**

**Article 1 :** To appoiut Tan Sri Dr.Chen Lip Keong as an Economic Advisor to samdech Hun sen, prime Minister of the Royal Government of Cambodia

**Article 2 :** Tan sri Dr Chen Lip Keong has to implement this decision from the date of its signature .

Phnom Penh june 5 th 2001

HUN SEN
Prime Minister

===

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ៣១ សសរ**
**ស្តីពីការបង្កើតគណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យ**
**ករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម ឈុន យ៉ាសិទ្ធិ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១៩៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-លិខិតលេខ ៥៣៣ រប-២០០១ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១ របស់ក្រសួងយុត្តិធម៌

-ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

-យោងតាមការចាំបាច់

**សំរេច**

**ប្រការ ១** : ត្រូវបានបង្កើតគណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម **ឈុន យ៉ាសិទ្ធិ** ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សូរ ផន** អគ្គនាយករងទី១នគរបាលជាតិ ជាប្រធាន

២-ឯកឧត្តម **ប្រាក់ ស៊ីហារ៉ា** អគ្គនាយករងទី១ អគ្គរដ្ឋបាល ជាអនុប្រធាន

៣-លោកឧត្តមសេនីយ៍ទោ **នេត សាវឿន** ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ អនុប្រធានអចិន្ត្រៃយ៍

៤-លោកឧត្តមសេនីយ៍ត្រី **វង្ស ពិសេន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ អនុប្រធាន

៥-លោកឧត្តមសេនីយ៍ត្រី **ម៉ូ លីដា** អនុប្រធានទី១នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ សមាជិក

៦-លោកឧត្តមសេនីយ៍ត្រី **សុខ ផល** ប្រធាននាយកដ្ឋានពត៌មានទូទៅ សមាជិក

៧-លោកឧត្តមសេនីយ៍ត្រី **គន្ធ សំអឿន** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម សមាជិក

៨-លោកឧត្តមសេនីយ៍ត្រី **សួន ឈាងលី** ស្នងការនគរបាលក្រុងភ្នំពេញ សមាជិក

៩-លោកឧត្តមសេនីយ៍ត្រី **ឡៅ ស៊ីនផា** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ សមាជិក

១០-លោកឧត្តមសេនីយ៍ត្រី **ហុក ធីន** ប្រធាននាយកដ្ឋានតម្រួតការពារ សមាជិក

១១-លោក **ស្រេង ស្រ៊ាង** ប្រធានស្តីទីនាយកដ្ឋានពន្ធដារ សមាជិក

១២-លោក **ឈឹម នី** អនុប្រធានទី១នាយកដ្ឋានពន្ធនាគារ សមាជិក

**ប្រការ ២** : គណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម **ឈុន យ៉ាសិទ្ធិ** មានភារកិច្ច :

-រៀបចំគំរោងផែនការការពារសុវត្ថិភាពដល់ដំណើរការនៃអង្គសវនាការទាំងស្រុង

-ការពារសុវត្ថិភាព ការដឹកជញ្ជូនទៅ មកពិរុទ្ធជនពីចំណុច ម១ មកកាន់ទីកន្លែងសវនាការ

-ការពារកន្លែងឃុំខ្លួនពិរុទ្ធជនជាបណ្ដោះអាសន្ន រងចាំការបើកសវនាការ

-ការពារសុវត្ថិភាពកន្លែងបើកសវនាការ

-ទប់ស្កាត់នឹងបង្ក្រាបអោយបានទាន់ពេលវេលារាល់ការប៉ុនប៉ងវាយរំដោះពិរុទ្ធជន ក្នុងគ្រប់ករណី និងគ្រប់កាលៈទេសៈ

-ទប់ស្កាត់ និងបង្ក្រាបអោយបានទាន់ពេលវេលារាល់ការប៉ុនប៉ងផ្សេងៗ ដែលសំដៅបង្កការវិខាន ឬ ធ្វើអោយរាំងស្ទះដល់ការបើកសវនាការ

-រៀបចំសណ្ដាប់ធ្នាប់បរិវេណខាងក្រៅអង្គពិធីសវនាការ

-ពង្រឹងការងារក្ដាប់សភាពការណ៍ ដែលពាក់ព័ន្ធដល់ដំណើរការសវនាការ

-អនុវត្តភារកិច្ចការពារផ្សេងៗទៀតដែលមានការពាក់ព័ន្ធ

**ប្រការ ៣** : គណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម **ឈុន យ៉ាសិទ្ធិ** ត្រូវមានកិច្ចសហប្រតិបត្តិការអោយបានជិតស្និទ្ធ ជាមួយអាជ្ញាធរ មានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តភារកិច្ចការពារអោយទទួលបានជោគជ័យ ។ គណៈបញ្ជាការការពារត្រូវកសាងផែនការឯកភាពមួយរវាងអគ្គនាយកដ្ឋាននគរបាលជាតិ ស្នងការដ្ឋាននគរបាលក្រុងភ្នំពេញ និងកងរាជអាវុធហត្ថក្រុងភ្នំពេញ ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គនាយក នៃអគ្គនាយកដ្ឋាននគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តសេចក្ដីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រីស្ដីទី

ហត្ថលេខា និងត្រា

**ស ខេង**

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ៣២ សសរ**

**ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រី**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញសេចក្តីសំរេចលេខ ២៩ សសរ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការផ្ទេរសិទ្ធិនៃរាជរដ្ឋាភិបាល

-យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :**

ផ្ទេរសិទ្ធិជូនឯកឧត្តម **ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ទទួលបន្ទុកបន្ថែម ជារដ្ឋមន្ត្រីស្តីទីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជំនួសឯកឧត្តម **ច័ន្ទ សារុន** ដែលត្រូវបានអញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេសដោយគិតចាប់ពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០១ រហូតដល់ឯកឧត្តម **ច័ន្ទ សារុន** អញ្ជើញវិលត្រឡប់វិញ ។

**ប្រការ ២ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាល ខេត្ត-ក្រុង និងឯកឧត្តម **ម៉ុក ម៉ារ៉េត** ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

**ស ខេង**

## III. ការងារបណ្ដាក្រសួង

### ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាស**

**ប្រកាសលេខ ៣៨៧ ឧរថ ឧតស.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្ដេចព្រះ **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ ស្ដីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញប្រកាសលេខ ១៧៦ ផក.ប្រក ចុះថ្ងៃទី ០៣-៣-៩៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតគ្រឿងបន្លាស់អំពីកៅស៊ូសំរាប់ ម៉ូតូ រថយន្ត របស់លោក **សោម ស៊ីង** ចុះថ្ងៃទី ១៦-០២-០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយលោក **សោម ស៊ីង** ជនជាតិខ្មែរ កាន់អត្តសញ្ញាប័ណ្ណលេខ ០០៧៥៦៥ ក.ក ចុះថ្ងៃទី ០២-០១-៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២២៥ ក្រុមទី៨ ភូមិថ្មី ឃុំតាខ្មៅ ស្រុកតាខ្មៅ

ខេត្តកណ្តាល បន្តដំណើរការឧស្សាហកម្មតូចផលិតគ្រឿងបន្លាស់អំពីកៅស៊ូសំរាប់ ម៉ូតូ រថយន្ត នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២** : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៣** : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង លោក **សោម ស៊ីទ** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ ៤** : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

===

រាជធានីភ្នំពេញ . ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាសលេខ ៣៨៨ ឧរថ ឧតស.ប្រក

---

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញប្រកាសលេខ ២៧៩ ផក.ប្រក ចុះថ្ងៃទី ០៨-៤-៩៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចផលិតប្រេងរំអិល " COSMIC " របស់លោក **ទិញ ទ្រី** ចុះថ្ងៃទី ១៩-៣-០១

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយលោក **ទិញ ទ្រី** ជនជាតិខ្មែរ កាន់អត្តសញ្ញាប័ណ្ណលេខ ១០០៤៥៧ ភ.ព ចុះថ្ងៃទី ១៩-៨-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៧៤ ផ្លូវលេខ ៦៤៤ សង្កាត់ច្បារអំពៅទី២ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូចផលិតប្រេងរំអិល " COSMIC " នៅក្នុងទីតាំង ភូមិទឹកជា ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**ប្រការ ២** : លោក **ទិញ ទ្រី** ត្រូវមកចុះបញ្ជីផលិតផល និង យកគំរូផលិតផលប្រេងរំអិលរបស់ខ្លួនមកពិនិត្យគុណភាព នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មុននឹងចរាចរនៅលើទីផ្សារ ។

**ប្រការ ៣** : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៤** : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង លោក **ទិញ ទ្រី** ត្រូវទទួលអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

**ប្រការ ៥** : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

===

រាជធានីភ្នំពេញ . ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០១

# ប្រកាសលេខ ៤០០ ឧរថក ឱ.ប្រក

# រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់កសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ១១៧២/០១ គ.វ.ក ចុះថ្ងៃទី ២៥-០៤-២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ៤៩០/៩៨ ក.អ.ភ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ១២៤ ប.ស្ថ.ប្រ.ក វហបស្ថ ចុះថ្ងៃទី ២៥-០៥-២០០១ របស់ក្រសួងបរិស្ថាន

-បានឃើញលិខិតលេខ ៣១៤៩ លអ.ស ចុះថ្ងៃទី ១៤-១២-០០ របស់សាលាក្រុងភ្នំពេញស្តីពីការអនុញ្ញាតអោយសាងសង់អគារកាត់ដេរ

-យោងពាក្យស្នើរបស់ក្រុមហ៊ុន ឡាយន៍ ហ្វា ហ្គាមិន ខូ អិលធិឌី ចុះថ្ងៃទី ២៥-០៥-២០០១

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន " ឡាយន៍ ហ្វា ហ្គាមិន ខូ អិលធីឌី " ( LINE FA GARMENT CO,LTD ) តំណាងដោយលោក **លី ហុងយួន** អាយុ ៤៦ ឆ្នាំ ភេទ ប្រុស សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣៧៩១១៧ ភ.៣ ចុះថ្ងៃទី ៣០-៦-៩៣ បង្កើតរោងចក្រ " កាត់ដេរ សំលៀក

បំពាក់ " ដែលមាន ផ្លាកឈ្មោះថា " ឡាយន៍ ហ្វា ហ្គាមិន " មានទីតាំងស្ថិតនៅ ដីឡូត៍គ្មានលេខ ផ្លូវលំទំនប់ថ្មី ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការរៀបចំអាគារនិងគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ០៦ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

**ប្រការ ៣ :** រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់ដេរសំលៀកបំពាក់ " ទៅតាមគំរូដែលតំកល់ទុក ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៤ :** ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធ នឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ ៥ :** ការពង្រីកផលិតកម្មផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំង ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀតនៅកន្លែងដែលងាយមើលឃើញ នៅខាងមុខរោងចក្រ ។

**ប្រការ ៧ :** រាល់ការនាំចេញផលិតសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៨ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៩ :** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញនិង ប្រធានក្រុមហ៊ុន ឡាយន៍ ហ្វា ហ្គាមិន ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ ១០ :** ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

## ប្រកាស

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាសលេខ ៣៩៨ អយក.ប្រក**

**ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ "រលាប្អៀរជើង "**

**ទៅជាវិទ្យាល័យ " ហ៊ុន សែន រលាប្អៀរ "**

**ស្ថិតនៅក្នុង ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១ កំរិត ២

-យោងលិខិតស្នើសុំរបស់នាយកអនុវិទ្យាល័យរលាប្អៀរជើង លេខ ៨៧-២០០០ អនុ.រលបជ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ឆ្នាំង

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ " **រលាប្អៀរជើង** " បច្ចុប្បន្ន ទៅជាវិទ្យាល័យ " **ហ៊ុន សែន រលាប្អៀរ** " ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ តទៅ ។

**ប្រការ ២** : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ឆ្នាំង និង នាយកវិទ្យាល័យសាមី នាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**អ៊ឹម សិទ្ធី**

===

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាសលេខ ៤០០ អយក.ប្រក

## ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ "រលាប្អៀរត្បូង" ទៅជាវិទ្យាល័យ " ប៊ុន រ៉ានី ហ៊ុន សែន រលាប្អៀរ " ស្ថិតនៅភូមិ ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទិ ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពិការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ឆ្នាំ ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១ កំរិត ២

-យោងលិខិតស្នើសុំរបស់នាយកអនុវិទ្យាល័យរលាប្អៀរត្បូង លេខ ៤៤-៩៧ រលបត ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ឆ្នាំង

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ " **រលាប្អៀរត្បូង** " បច្ចុប្បន្ន ទៅជាវិទ្យាល័យ " **ប៊ុន រ៉ានី ហ៊ុន សែន រលាប្អៀរ** " ចាប់ពីឆ្នាំសិក្សា ២០០០-២០០១ តទៅ ។

**ប្រការ ២** : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ៗ

**ប្រការ ៥** : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួង

អប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ឆ្នាំង និង នាយកវិទ្យាល័យ សាមិ នាយកវិទ្យាល័យសាមី មានភារកិច្ចរៀង១ខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**អ៊ឹម សិទ្ធី**

===

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាសលេខ ៤០៤ អយក.ប្រក
## ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ "បរិបូណ៌"
## ទៅជាវិទ្យាល័យ " ហ៊ុន សែន បរិបូណ៌ "
## ស្ថិតនៅក្នុង ឃុំខ្នាវែង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ឆ្នាំ ១៩៨៣ ស្ដីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១ កំរិត ២

-យោងលិខិតស្នើសុំរបស់នាយកអនុវិទ្យាល័យបរិបូណ៌ លេខ ១២០ វិ.បប ចុះថ្ងៃ ទី ២១ ខែ តុលា ឆ្នាំ ២០០០ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាល ខេត្តកំពង់ឆ្នាំង

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយពង្រីក និងប្ដូរឈ្មោះអនុវិទ្យាល័យ " **បរិបូណ៌** " បច្ចុប្បន្ន ទៅជា **វិទ្យាល័យ " ហ៊ុន សែន បរិបូណ៌ "** ចាប់ពីឆ្នាំសិក្សា ២០០០ ២០០១ តទៅ ។

**ប្រការ ២** : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥** : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ឆ្នាំង និង នាយកវិទ្យាល័យ សាមីនាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

**អ៊ឹម សិទ្ធី**

===

## ៣~ ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាស

### ប្រកាសលេខ ១២៤ ស.ក.ប.យ
### ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច
### ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញស្មារតីនៃអង្គប្រជុំគណៈកម្មការប្រឹក្សាការងារ

### សំរេច

**ប្រការ ១** : និយោជក នៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង មាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់វិរះរកមធ្យោបាយចាំបាច់ ដើម្បីជៀសវាងកុំអោយការលើកដាក់ទម្ងន់មានគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ពិសេសកុំអោយមានការប៉ះពាល់ដល់ឆ្អឹងខ្នង ។

ក្នុងករណីដែលការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្មផ្ទាល់មិនអាចជៀសវាងបានទេ ត្រូវធ្វើយ៉ាងណាកុំអោយការងារទាំងនោះបង្កគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ។

ការលើកដាក់ទម្ងន់ សំរាប់កម្មករនិយោជិតម្នាក់ ឬច្រើននាក់ ជាអាទិ៍ :

-ការលើក

-ការដឹកនាំ

-ការដាក់ចុះ

-ការរុញ

-ការអូសទាញ

-ការរំកិល វត្ថុ ដែលមានទម្ងន់ដោយបញ្ចេញកម្លាំពលកម្មផ្ទាល់ ។

**ប្រការ ២** : ដើម្បីជាវិធានការល្អក្នុងការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្មផ្ទាល់នេះ និយោជកត្រូវ :

-រៀបចំកញ្ចប់ទម្ងន់នីមួយៗកុំអោយទើសទែងនិងមិនលើសពី ៥០ គីឡូក្រាម

-រៀបចំផ្លូវឆ្លងកាត់អោយបានជិតបំផុតនិងមិនយ៉ាប់ធ្វើដំណើរ

-រៀបចំកម្មករនិយោជិតដែលចូលរួមធ្វើការលើកដាក់ទម្ងន់ដោយមិនបង្ខិតបង្ខំ

-រិះរកមធ្យោបាយបច្ចេកទេសជំនួយក្នុងការលើកដាក់ទម្ងន់

-ផ្តល់ដល់កម្មករនិយោជិតនូវការអប់រំបច្ចេកទេសលើកដាក់ទម្ងន់

**ប្រការ ៣** : ស្ត្រីមានផ្ទៃពោះ ឬស្ត្រីទើបចូលធ្វើការឡើងវិញបន្ទាប់ពីសំរាលកូន ឬរលូតកូន ឬរំលូតកូន ក្នុងរយៈពេល ២ ខែ ដំបូង មិនអនុញ្ញាតអោយលើកទម្ងន់លើសពី ៥គីឡូក្រាម

**ប្រការ ៤** : កម្មករនិយោជិតម្នាក់ មិនអនុញ្ញាតអោយ លើក ដាក់ អូស ទាញ រុញ ឬរំកិលទម្ងន់ ដោយកម្លាំងពលកម្មផ្ទាល់ ដែលមានចំនួនលើសពីទម្ងន់ដែលមានបង្ហាញក្នុងតារាងខាងក្រោមនេះ :

| សណ្ឋាននៃទម្ងន់ | បុរស | | ស្ត្រី | |
|---|---|---|---|---|
| | ចាប់ពី ១៥ ឆ្នាំ | ចាប់ពី ១៨ ឆ្នាំ | ចាប់ពី ១៥ ឆ្នាំ | ចាប់ពី ១៨ ឆ្នាំ |
| លើកដាក់ទម្ងន់ផ្ទាល់ | ១២គ.ក្រ | ៥០គ.ក្រ | ៦គ.ក្រ | ២៥គ.ក្រ |
| រទេះរុញកង់១ ផ្លូវក្នុងការដ្ឋាន | ៣២គ.ក្រ | ៨០គ.ក្រ | ហាម | ៤០គ.ក្រ |
| រទេះរុញកង់៣ឬ៤ ផ្លូវក្នុងការដ្ឋាន | ៤៨គ.ក្រ | ១២០គ.ក្រ | ២៤គ.ក្រ | ៦០គ.ក្រ |

**ប្រការ ៥** : បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន អាចបញ្ជាក់ពីសេចក្ដីច្បាស់លាស់នៃការរៀបចំការងារ លើកដាក់ទម្ងន់ ។ ក៏ប៉ុន្តែសេចក្ដីបញ្ជាក់នៃបទបញ្ជាផ្ទៃក្នុងនេះ មិនអាចផ្ទុយពីប្រការទាំងឡាយ នៃប្រកាសនេះឡើយ ។

**ប្រការ ៦** : ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុង ជំពូកទី ១៦ នៃច្បាប់ស្ដីពីការងារ ។

**ប្រការ ៧** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**អ៊ិត សំហេង**

===

## ៤~ ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាស**

**ប្រកាសលេខ ១៩៦ ប្រក.សក.បធ**

**ស្ដីពីការតែងតាំងមន្ត្រី រាជការ**

**រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្ដម សីហនុ** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជាលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើត ក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤/អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញលិខិតលេខ ១៣៣/មស.តត ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១ របស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-យោងតាមការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** តែងតាំងលោក **សេក ដារិន** ជានាយករងមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តក្រចេះ នៃ ក្រសួង សាធារណការ និង ដឹកជញ្ជូន ។

**ប្រការ ២ :** លោកនាយកខុទ្ទកាល័យ ឯកឧត្ដមអគ្គនាយក រដ្ឋបាល ឯកឧត្ដម អគ្គនាយកសាធារណការ លោកនាយកមន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តក្រចេះ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុក អនុវត្តរៀងៗខ្លួន តាមខ្លឹមសារ នៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ហត្ថលេខានិងត្រា

**ឃី តាំងលីម**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ ខែ_____ ឆ្នាំ_______

====

=